**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីបញ្ជាក់បន្ថែម
## អំពី
## ប្រភេទរោងចក្រ សហគ្រាស និងសិប្បកម្ម ដែលអាចស្នើសុំបុគ្គលិកចាំបាច់បំផុតដើម្បីប្រចាំការ និងអំពីឯកសារតម្រូវក្នុងពេលធ្វើដំណើរទៅបំពេញការងារ ឬប្រកបមុខរបរ ឬអាជីវកម្ម

យោងសេចក្តីសម្រេចលេខ ៤៩ សសរ របស់រាជរដ្ឋាភិបាល ស្តីពីការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងសេចក្តីសម្រេចលេខ ០៤២/២១ កប/សសរ.ខល របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីប្រភេទរោងចក្រ សហគ្រាស និងសិប្បកម្មដែលត្រូវបានអនុញ្ញាតឱ្យដំណើរការសកម្មភាពអាជីវកម្មក្នុងអំឡុងពេលនៃការអនុវត្តវិធានការបិទខ្ទប់ជាបណ្តោះអាសន្ននូវភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល នោះក្រសួងសូមបញ្ជាក់បន្ថែមដល់លោក លោកស្រីជាម្ចាស់ ឬនាយករោងចក្រ សហគ្រាស និងសិប្បកម្មថា មានតែរោងចក្រ សហគ្រាស និងសិប្បកម្ម ដែលមានកម្មករនិយោជិតលើសពី ៣០០នាក់ ក្នុង ១ទីតាំង ហើយមានតម្រូវការចាំបាច់ឱ្យមានបុគ្គលិកថែទាំវត្ថុធាតុដើម និងសន្និធិផលិតផលប៉ុណ្ណោះ ដែលអនុញ្ញាតឱ្យមានបុគ្គលិកចាំបាច់មិនលើសចំនួន ២៥នាក់ ធ្វើការនៅលើទីតាំងផលិតកម្មរបស់ខ្លួន។ ក្រុមហ៊ុន រោងចក្រ សហគ្រាស និងសិប្បកម្មទូទៅ គឺមិនអនុញ្ញាតឱ្យមានបុគ្គលិកធ្វើការនៅលើទីតាំងឡើយក្នុងអំឡុងពេលនៃការបិទខ្ទប់ជាបណ្តោះអាសន្ននេះ។

ដើម្បីសម្រួលដល់ការធ្វើដំណើរទៅបំពេញការងារ ឬប្រកបមុខរបរ ឬអាជីវកម្ម សូមលោក លោកស្រីជាម្ចាស់ ឬនាយករោងចក្រ សហគ្រាស និងសិប្បកម្ម ទាំង១១ប្រភេទ ដែលត្រូវបានអនុញ្ញាតឱ្យបន្តដំណើរការសកម្មភាពអាជីវកម្មក្នុងអំឡុងពេលនៃការបិទខ្ទប់នេះ ផ្តល់ឯកសារបញ្ជាក់អំពីការងារ មុខរបរ ឬអាជីវកម្ម ដល់បុគ្គលិករបស់ខ្លួន និងណែនាំដល់បុគ្គលិករបស់ខ្លួនឱ្យយកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬប័ណ្ណសម្គាល់ខ្លួនតាមខ្លួនជានិច្ច ដើម្បីបង្ហាញជូនសមត្ថកិច្ចនៅពេលធ្វើដំណើរ។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល នឹងបន្តផ្តល់ "លិខិតអនុញ្ញាតចេញ-ចូល" ទៅតាមសំណូមពរ និងតម្រូវការជាក់ស្តែងដល់តំណាងរោងចក្រ សហគ្រាស និងសិប្បកម្ម ដែលត្រូវបានអនុញ្ញាតឱ្យដំណើរការសកម្មភាពអាជីវកម្មក្នុងអំឡុងពេលនៃការអនុវត្តវិធានការបិទខ្ទប់ជាបណ្តោះអាសន្ននៅរៀងរាល់ម៉ោងធ្វើការ។

ក្រសួងសូមអំពាវនាវដល់គ្រប់ម្ចាស់ ឬនាយករោងចក្រ សហគ្រាស និងសិប្បកម្មទាំងអស់មេត្តាអត់ធ្មត់ និងចូលរួមអនុវត្តវិធានការបិទខ្ទប់នេះឱ្យបានល្អដើម្បីយើងឆាប់កាត់ផ្តាច់ឫសគល់នៃព្រឹត្តិការណ៍ឆ្លងសហគមន៍-២០កុម្ភៈ និងវិលត្រឡប់មករកភាពប្រក្រតីកម្មនៃគ្រប់សកម្មភាពអាជីវកម្មវិញ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោក លោកស្រីជាម្ចាស់ ឬនាយករោងចក្រ សហគ្រាស និងសិប្បកម្ម ព្រមទាំងសាធារណជនជ្រាបជាព័ត៌មាន។

ថ្ងៃសុក្រ ៥កើត ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២១

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ:(០២៣) ៨៨ ២៧ ៦៥